ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ២៥៣១ មស.សណាន

# សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីនៃការបើកផ្តល់ប្រាក់កម្រៃជូនគ្រូបង្រៀនជាប់កិច្ចសន្យា តាមប្រព័ន្ធព័ត៌មានវិទ្យា

យោងអនុក្រឹត្យលេខ៣០៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ សេចក្តីណែនាំលេខ៤៩៨ មស.សណន ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យានៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ ក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពគ្រប់គ្រងការប្រើប្រាស់និងការបើកផ្តល់ប្រាក់កម្រៃប្រកបដោយការទទួលខុសត្រូវនិងគណនេយ្យភាពខ្ពស់ ក្រសួងមុខងារសាធារណៈ សូមជម្រាបដល់មន្ទីរនិងអង្គភាពជំនាញរាជធានី ខេត្ត ដែលគ្រប់គ្រងការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាដូចខាងក្រោម៖

១. ក្រោយពីទទួលតារាងឧបសម្ព័ន្ធស្តីពីការបែងចែកក្របខណ្ឌ មន្ត្រីជាប់កិច្ចសន្យា និងគ្រូបង្រៀនជាប់កិច្ចសន្យាផ្សេងទៀតរបស់ក្រសួងមុខងារសាធារណៈ មន្ទីរអប់រំ យុវជន និងកីឡា និងអង្គភាពពាក់ព័ន្ធត្រូវរៀបចំជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាអនុលោមតាមនីតិវិធីជាធរមាន និងត្រូវធ្វើស្វ័យប្រកាសព្រមទាំងបំពេញប្រវត្តិរូបសង្ខេបដូចមានក្នុងគំរូឧបសម្ព័ន្ធ១និង២ដូចមានជូនភ្ជាប់។

២. មន្ទីរអប់រំ យុវជន និងកីឡា ត្រូវផ្តល់ឯកសារមានជាអាទិ៍ ១.ស្វ័យប្រកាស ២.ប្រវត្តិរូបសង្ខេប និង ៣.ឯកសារពាក់ព័ន្ធផ្សេងទៀត ដល់មន្ទីរមុខងារសាធារណៈ ដើម្បីរៀបចំទិន្នន័យដើមគ្រា។ ជារៀងរាល់ខែ មន្ទីរអប់រំ យុវជន និងកីឡា និងអង្គភាពពាក់ព័ន្ធ ត្រូវស្នើសុំធ្វើការប្រែប្រួលស្ថានភាពគ្រូបង្រៀនជាប់កិច្ចសន្យា ឱ្យបានមុនដំណាច់សប្តាហ៍ទី២នៃខែនីមួយៗ ដើម្បីរៀបចំការបើកផ្តល់ប្រាក់កម្រៃក្នុងខែបន្ទាប់។

៣. មន្ទីរមុខងារសាធារណៈ មានភារកិច្ច៖
- ត្រួតពិនិត្យផ្ទៀងផ្ទាត់ឯកសារដូចមានក្នុងចំណុចទី២ខាងលើ
- បញ្ចូល ឬធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រូបង្រៀនជាប់កិច្ចសន្យាក្នុងប្រព័ន្ធគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ
- បង្កើតតារាងទូទាត់ប្រាក់កម្រៃប្រចាំខែរបស់គ្រូបង្រៀនជាប់កិច្ចសន្យាក្នុងប្រព័ន្ធគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យានិងអនុម័តតារាងនេះជាការបញ្ចប់ការកែប្រែ។

៤. មន្ទីរមុខងារសាធារណៈ ត្រូវផ្តល់តារាងទូទាត់ប្រាក់កម្រៃដែលបានអនុម័តរួចជូនមន្ទីរអប់រំ យុវជន និងកីឡា យ៉ាងយូរត្រឹមសប្តាហ៍ទី៤នៃខែនីមួយៗ ដើម្បីរៀបចំអាណត្តិបើកផ្តល់ប្រាក់កម្រៃខែបន្ទាប់។



ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

៥. មន្ទីរអប់រំ យុវជន និងកីឡា ត្រូវអនុវត្តនីតិវិធីបើកផ្តល់ប្រាក់កម្រៃជូនគ្រូបង្រៀនជាប់កិច្ចសន្យាដោយអនុវត្តអនុលោមតាមស្មារតីនៃសារាចរលេខ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗជូនមន្ត្រីរាជការស៊ីវិលនិងមន្ត្រីសាធារណៈផ្សេងទៀត។ ការបើកផ្តល់ប្រាក់កម្រៃគ្រូបង្រៀនជាប់កិច្ចសន្យាត្រូវអនុវត្តតាមប្រព័ន្ធធនាគារ ដោយផ្អែកលើតារាងទូទាត់ប្រាក់កម្រៃដែលផ្តល់ដោយមន្ទីរមុខងារសាធារណៈ។

អគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ មានភារកិច្ចសម្របសម្រួលបណ្តុះបណ្តាល ដោះស្រាយបញ្ហាប្រឈម និងតាមដានត្រួតពិនិត្យការអនុវត្តនូវសេចក្តីណែនាំនេះ។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរនិងអង្គភាពជំនាញរាជធានី ខេត្ត ពាក់ព័ន្ធ ត្រូវទទួលខុសត្រូវនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ១១ រោច ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល៖**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងអប់រំ យុវជន និងកីឡា
- -រដ្ឋបាលរាជធានី ខេត្ត
- -មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- -មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត
- -មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- -ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃសេចក្តីណែនាំលេខ ២៥៣១ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៩ **គំរូ**

ស្តីពីការបើកផ្តល់ប្រាក់កម្រៃជូនគ្រូបង្រៀនជាប់កិច្ចសន្យា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត:** .......................................

**ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក:** .......................................

| |
|---|
| រូបថត<br>4x6 |

## ប្រវត្តិរូបសង្ខេប

### ក. ព័ត៌មានផ្ទាល់ខ្លួន

- នាមត្រកូល-នាមខ្លួន :.............................................................ភេទ..................សញ្ជាតិ....................
- អក្សរពុម្ពឡាតាំង :...............................................................................................................
- ថ្ងៃខែឆ្នាំកំណើត :...............................................................................................................
- ទីកន្លែងកំណើត :...............................................................................................................
- កម្រិតវប្បធម៌ :...............................................................................................................
- លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ:..........................................................................................
- ឈ្មោះធនាគារ :.................................... លេខគណនីធនាគារ :................................................

### ខ. ព័ត៌មានទំនាក់ទំនង

- អាសយដ្ឋានបច្ចុប្បន្ន :...............................................................................................................
- លេខទូរស័ព្ទ :...............................................................................................................
- អ៊ីម៉ែល (ប្រសិនបើមាន) :...............................................................................................................

### គ. ស្ថានភាពការងារ

- ខេត្ត:......................... ក្រុង/ស្រុក: ......................... ឃុំ/សង្កាត់:......................... ភូមិ:............................
- ប្រភេទគ្រូបង្រៀនជាប់កិច្ចសន្យា: ☐ចំណេះដឹងទូទៅ ☐ ពហុភាសា ☐ខ្មែរជស្លាម
- កម្រិតថ្នាក់ទី:............ ជ្រើសចេញពី: ☐ សិស្ស/និស្សិត ☐ គ្រូចូលនិវត្តន៍
- សាលារៀន:....................................
- ថ្ងៃចូលបម្រើការងារ:......................... ថ្ងៃបញ្ចប់ការងារ:.........................

ខ្ញុំសូមធានាអះអាងចំពោះព័ត៌មានខាងលើ ពិតជាត្រឹមត្រូវ។

សូមភ្ជាប់មកជាមួយនូវ៖ ១.សេចក្តីចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ២.សេចក្តីចម្លងបណ្ណធនាគារ ៣.ឯកសារបញ្ជាក់ជាគ្រូបង្រៀនចូលនិវត្តន៍(ចំពោះអតីតគ្រូបង្រៀន)

ធ្វើនៅ.......................ថ្ងៃទី........ខែ..........ឆ្នាំ............

ហត្ថលេខ/ស្នាមមេដៃសាមីខ្លួន

ឧបសម្ព័ន្ធទី២ នៃសេចក្តីណែនាំលេខ២៥៣១ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩

ស្តីពីការបើកផ្តល់ប្រាក់កម្រៃជូនគ្រូបង្រៀនជាប់កិច្ចសន្យា

**គំរូ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត:** .......................................

**ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង/ស្រុក:** .............................................. **សង្កាត់/ឃុំ:** .............................................. **ភូមិ:** ..............................................

**ការប្រកាស**

**អំពី**

**ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យានៅសាលាបឋមសិក្សា** .................................................

ក្នុងនាមគណៈគ្រប់គ្រងសាលាសម្រាប់ឆ្នាំសិក្សា ........................ ខ្ញុំសូមធ្វើការប្រកាសអំពីចំនួនជាក់ស្តែងនិងឈ្មោះពិតប្រាកដរបស់គ្រូបង្រៀនជាប់កិច្ចសន្យា ដែលកំពុងបង្រៀននៅសាលាបឋមសិក្សាស្ថិតក្រោមការគ្រប់គ្រងរបស់ខ្ញុំដូចមានក្នុងបញ្ជីរាយឈ្មោះខាងក្រោម៖

| ល.រ | គោត្តនាម-នាម | ភេទ | កម្រិតថ្នាក់ | ប្រភេទគ្រូបង្រៀន | ជ្រើសចេញពី | ថ្ងៃចូលបម្រើការងារ | ថ្ងៃបញ្ចប់ការងារ | ឈ្មោះធនាគារ | លេខគណនីធនាគារ |
|---|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | | |
| ២ | | | | | | | | | |
| ៣ | | | | | | | | | |
| ... | | | | | | | | | |
| ... | | | | | | | | | |

ខ្ញុំសូមធានាអះអាងថា ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាខាងលើ ពិតជាត្រឹមត្រូវ ជាក់ស្តែងពិតប្រាកដមែន៕

ធ្វើនៅ ...................... ថ្ងៃទី.........ខែ..........ឆ្នាំ២០១៩

**ជ.គណៈគ្រប់គ្រង**

**នាយកសាលា**